June 14, 2019

# ក្រោយបេសកកម្មនៅកម្ពុជា EU ប្ដេជ្ញាធ្វើការជាមួយភាគីកម្ពុជា ដើម្បីដោះស្រាយរឿងEBA



ទីស្នាក់ការកណ្ដាលរបស់គណៈកម្មការសហភាពអឺរ៉ុបនៅទីក្រុងព្រុចសែល (រូបភាពតំណាង) REUTERS/Francois Lenoir

**ដោយ សឿង ភារៈ rfi13/06/2019**

*សហភាពអឺរ៉ុបប្ដេជ្ញាធ្វើការជាមួយអាជ្ញាធរកម្ពុជា ដោះស្រាយបញ្ហាសិទ្ធិមនុស្ស និងសិទ្ធិការងារ ហើយកម្ពុជាត្រូវតែចូលរួមធ្វើយ៉ាងណាបង្ហាញនូវការវិវឌ្ឍន៍ទៅរកចំណុចល្អ ដើម្បីរក្សាប្រព័ន្ធអនុគ្រោះពន្ធEBA។ នេះជាការអះអាងរបស់ប្រតិភូពិសេសអឺរ៉ុប ក្រោយបេសកកម្មស្វែងរកការពិតនៅកម្ពុជាកាលពីដើមខែមិថុនា។*

*តាមរយៈបេសកកម្មស្វែងរកការពិតនៅក្នុងកម្ពុជាប្រតិភូអឺរ៉ុបបានបានជួបមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល អង្គការអន្តរជាតិ សហជីព ស្ថាប័នជំនួញ អង្គការសង្គមស៊ីវិល និងមន្ត្រីទូត ដែលជាសមាជិករបស់សហភាពអឺរ៉ុបនៅកម្ពុជា។ នេះបើយោងតាមគេហទំព័ររបស់គណៈកម្មការអឺរ៉ុបកាលពីថ្ងៃទី១១ ខែមិថុនា។*

*គោលដៅរបស់សហភាពអឺរ៉ុបគឺធ្វើយ៉ាងណាដោះស្រាយបញ្ហាសិទ្ធិមនុស្ស និងសិទ្ធិការងារ ហើយសហភាពអឺរ៉ុបនឹងធ្វើការជាមួយអាជ្ញាធរកម្ពុជាលើបញ្ហានេះ។ ហើយកម្ពុជាត្រូវតែចូលរួមធ្វើយ៉ាងណាបង្ហាញនូវការវិវឌ្ឍន៍ទៅរកចំណុចល្អ ដើម្បីរក្សាប្រព័ន្ធអនុគ្រោះពន្ធEBA។*

ដំណាក់កាលនៃការឃ្លាំមើល និងវាយតម្លៃពីស្ថានភាពនៅក្នុងប្រទេសកម្ពុជានឹងត្រូវបញ្ចប់នៅពាក់កណ្តាលខែសីហាខាងមុខ ហើយសហភាពអឺរ៉ុបនឹងចងក្រងជារបាយការណ៍មួយស្តីពីការស្វែងរកឃើញរបស់ខ្លួន នៅកម្ពុជា។ សហភាពអឺរ៉ុបឲ្យដឹងថា រដ្ឋាភិបាលកម្ពុជាមានរយៈពេលមួយខែក្នុងការឆ្លើយតបទៅនឹងរបាយការណ៍នេះ។

សូមជម្រាបជូនជូនថា កាលពីថ្ងៃទី៣ ដល់ថ្ងៃទី១០ ខែមិថុនាកន្លងទៅប្រតិភូពីគណៈកម្មការអឺរ៉ុបបានបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជាដើម្បីឃ្លាំមើល និងសិក្សាស្ថានភាពសិទ្ធិមនុស្ស និងសិទ្ធិការងារ នៅក្នុងដំណើរការដែលអាចឈានទៅព្យួរជាបណ្តោះអាសន្នប្រព័ន្ធអនុគ្រោះពន្ធ អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ(EBA)ពីកម្ពុជា។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាថ្លែងអំណរគុណចំពោះកិច្ចសហការរវាងគណៈកម្មការអឺរ៉ុប និងរដ្ឋាភិបាល ក្នុងពេលចុះមកវាយតម្លៃពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ លោកបន្តថារដ្ឋាភិបាលកម្ពុជាប្តេជ្ញាបំពេញនូវរាល់អ្វី ដែលជាកាតព្វកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌរបស់សហភាពអឺរ៉ុប បន្ថែមពីនេះ រដ្ឋាភិបាលនឹងបំពេញតួនាទីជាអ្នកទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋកម្ពុជា។

យ៉ាងណាក៏ដោយ លោក ផៃ ស៊ីផាន បញ្ជាក់ថា រដ្ឋាភិបាលកម្ពុជានឹងមិនទទួលយកការប្រើប្រាស់ប្រព័ន្ធអនុគ្រោះពន្ធ EBA ដើម្បីយកកម្ពុជាធ្វើជាចំណាប់ខ្មាំងជាដាច់ខាត។

សូមជម្រាបជូនថា ដំណើរមកដល់ជាបន្តបន្ទាប់នៃគណៈប្រតិភូសហភាពអឺរ៉ុបនេះ ធ្វើឡើងក្រោយពីអឺរ៉ុបបានប្រកាសដាក់ចេញនូវដំណើរការនីតិវិធីព្យួរ ប្រព័ន្ធអនុគ្រោះពន្ធ (EBA) ពីកម្ពុជា កាលពីខែកុម្ភៈកន្លងទៅ។ តាមនីតិវិធី ដំណើរការនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធ (EBA) ត្រូវធ្វើឡើងជា ៣ដំណាក់កាល។ ដំណាក់កាលទីមួយ មានរយៈពេល ៦ខែ គឺជាពេលវេលាសម្រាប់តាមដាន ប្រមូលព័ត៌មាន និងចរចាជាមួយភាគីរដ្ឋាភិបាលកម្ពុជា។ ដំណាក់កាលទីពីរ មានរយៈ៦ខែ ដោយចែកចេញជាពីរផ្នែក គឺ ៣ខែ សម្រាប់សរសេររបាយការណ៍ និង ៣ខែទៀត សម្រាប់ស្តាប់ចម្លើយតបពីភាគីកម្ពុជា និងឈានទៅសម្រេចថាតើសហភាពអឺរ៉ុប ត្រូវព្យួរ ឬមិនព្យួរ EBA។ ចំណែក ដំណាក់កាលចុងក្រោយ ប្រសិនបើសហភាពអឺរ៉ុបសម្រេចព្យួរEAB នោះ គេត្រូវទុកពេល ៦ខែទៀត ទើបសេចក្តីសម្រេចនេះចូលជាធរមានបាន៕